ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**ខ្លឹមសារស្តីពីជំនួបសម្តែងការគួរសមរបស់ ឯកឧត្តម គីម ឆាងយ៉ុង ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េ ប្រចាំកម្ពុជា ចំពោះឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៦ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** ជារដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឱ្យ **ឯកឧត្តម គីម ឆាងយ៉ុង** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋកូរ៉េ (សា.កូរ៉េ) ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម នៅទីស្តីការក្រសួង។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍ និងអបអរសាទរយ៉ាងកក់ក្តៅចំពោះ**ឯកឧត្តម គីម ឆាងយ៉ុង** ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតប្រចាំកម្ពុជា។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងការពេញចិត្តចំពោះស្ថានភាពដ៏ល្អប្រសើរ និងស្និទ្ធស្នាលនៃទំនាក់ទំនងទ្វេភាគី និងវឌ្ឍនភាពជាលំដាប់នៃកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្ការវាងកម្ពុជា និងសា.កូរ៉េ លើវិស័យជាច្រើន ដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក រួមមាន ពាណិជ្ជកម្ម និងវិនិយោគ ការពារជាតិ និងសន្តិសុខ អប់រំ និងការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជន។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីសារៈសំខាន់នៃភាពជាដៃគូយុទ្ធសាស្ត្ររវាងប្រទេសទាំងពីរ ដែលត្រូវបានដំឡើងក្នុងអំឡុងដំណើរទស្សនកិច្ចផ្លូវការរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីកម្ពុជា** នៅសា.កូរ៉េ ក្នុងខែឧសភា ឆ្នាំ២០២៤។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ថា ក្រសួងការបរទេសនឹងបន្តផ្តល់កិច្ចសហប្រតិបត្តិការ និងកិច្ចសម្របសម្រួលជិតស្និទ្ធជាមួយ**ឯកអគ្គរដ្ឋទូត គីម ឆាងយ៉ុង** និងស្ថានទូតសា.កូរ៉េ នៅភ្នំពេញ ដើម្បីពង្រឹងទំនាក់ទំនងទ្វេភាគី និងពង្រីកកិច្ចសហប្រតិបត្តិការសម្រាប់ផលប្រយោជន៍ទៅវិញទៅមកនៃប្រជាជនទាំងពីរ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះសាធារណរដ្ឋកូរ៉េ សម្រាប់ជំនួយអភិវឌ្ឍន៍ផ្លូវការជាបន្តបន្ទាប់ ដែលរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា។

ជាការឆ្លើយតប **ឯកឧត្តមឯកអគ្គរដ្ឋទូត គីម ឆាងយ៉ុង** ក៏បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការល្អរវាងប្រទេសទាំងពីរ និងសមិទ្ធផលរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន រួមទាំងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។ ឯកឧត្តមឯកអគ្គរដ្ឋទូតក៏បានប្តេជ្ញាចិត្តក្នុងការធ្វើការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នពាក់ព័ន្ធកម្ពុជា ដើម្បីធ្វើឱ្យកាន់តែស៊ីជម្រៅនូវភាពជាដៃគូយុទ្ធសាស្ត្ររវាងប្រទេសទាំងពីរ ក្នុងអំឡុងពេលបេសកកម្មការទូតនៅកម្ពុជា។

ខណៈដែលឆ្នាំ២០២៧ ជាខួបលើកទី៣០ នៃការបង្កើតទំនាក់ទំនងការទូតឡើងវិញរវាងកម្ពុជា និងសា.កូរ៉េ ភាគីទាំងពីរបានបង្ហាញពីបំណងក្នុងការរៀបចំសកម្មភាពនានា ដើម្បីអបអរសាទរព្រឹត្តិការណ៍ដ៏សំខាន់នេះ ព្រមទាំងខិតខំជំរុញទំនាក់ទំនងទ្វេភាគីដល់កម្រិតថ្មីបន្ថែមទៀត ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានជម្រាបជូនឯកឧត្តម ឯកអគ្គរដ្ឋទូតពីស្ថានភាពបច្ចុប្បន្ននៃជម្លោះព្រំដែនកម្ពុជា-ថៃផងដែរ៕

ថ្ងៃអង្គារ ១រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៦